## អន្តរប្រិយ៍
### សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ព្រះសង្ឃខ្មែរកម្ពុជាក្រោមចំនួន៨៨អង្គ បានត្រូវប៉ូលិសវាយបង្ក្រាប ក្នុងឱកាសយកញត្តិទៅឲ្យស្ថានទូតយួននៅភ្នំពេញ ។

website: www.hoksavann.org

ថ្ងៃទី១៨ ធ្នូ ២០០៧



កាលពីថ្ងៃច័ន្ទ១៧ ធ្នូ ២០០៧ ព្រះសង្ឃខ្មែរកម្ពុជាក្រោមចំនួន៨៨អង្គ បានត្រូវប៉ូលិសវាយបង្ក្រាបដោយអំពើហិង្សា ក្នុងឱកាសនាំយកញត្តិទៅឲ្យទូតយួននៅភ្នំពេញដើម្បីទាមទារឲ្យដោះលែងព្រះសង្ឃខ្មែរក្រោមព្រះគ្រូទឹម-សាខន និងព្រះសង្ឃប្រាំអង្គទៀត ដែលយួនចាប់ផ្សឹកហើយដាក់គុក ។

តាមអ្នករាយការណ៍ពត៌មានឯករាជ្យ ផ្សេងពីការអះអាងរបស់អាជ្ញាធរខ្មែរថា ពុំមែនព្រះសង្ឃវាយប៉ូលិសមុនទេ គឺក្រុមប៉ូលិសទៅវាយបង្ក្រាបព្រះសង្ឃមុន ដើម្បីរារាំងកុំឲ្យតំណាងព្រះសង្ឃចូលទៅក្នុងស្ថានទូតយួន ដើម្បីប្រគល់ញត្តិ ។

ប៉ូលិសមានចំនួនពី១០០ទៅ២០០នាក់ ដែលមានកាំភ្លើងវែងខ្លីគ្រប់ដៃ និងដំបងឆក់ ព្រមទាំងខែលការពារខ្លួន ជាសញ្ញាថា អាជ្ញាធរខ្មែរបញ្ជាឲ្យទៅបង្ក្រាបតែម្តង ។

តាមយើងសង្កេត អំពើណាមួយ ទោះបីអំពើនោះប្រកបដោយអហិង្សាក៏ដោយ ឲ្យតែប៉ះពាល់ដល់វៀតណាម នឹងត្រូវគេចោទចាប់ដាក់គុក ឬត្រូវបង្ក្រាបដោយធម៌ហិង្សា ដូចព្រះសង្ឃ៨៨អង្គនេះជាដើម ។ នេះបញ្ជាក់ថា ខ្មែរពុំមែនឯករាជ្យទេ គឺពិតជានៅក្រោមអំណាចវៀតណាម ។

តាមការដោះស្រាយរបស់មេប៉ូលិសអ្នកបញ្ជាថា ពុំមែនប៉ូលិសវាយព្រះសង្ឃមុនទេ គឺព្រះសង្ឃវាយប៉ូលិសមុន ហើយប៉ូលិសគ្រាន់តែការពារខ្លួន ។ មេប៉ូលិសនោះបន្តថា ព្រះសង្ឃទាំងនោះចាត់ជាយុវជនស្មារ គេនឹងស្រាវជ្រាវមើល បើព្រះសង្ឃទាំងនោះ

ជាព្រះសង្ឃក្លែងក្លាយ គេនឹងធ្វើតាមច្បាប់ ។

ដោយមានគេថ្កោលទោសគ្រប់ទិស ទើបមេប៉ូលិសនោះប្រែសំដីវិញថា ទុកឲ្យក្រសួងធម្មការនិងកិច្ចការសាសនាពិនិត្យសង្កេតវិញ ។ ក្នុងពេលបង្ក្រាបនោះ ព្រះសង្ឃ៦អង្គបានត្រូវរបួសធ្ងន់ ហើយមានព្រះសង្ឃរបួសស្រាលជាច្រើនអង្គទៀត ។ ព្រះសង្ឃដែលត្រូវរបួសទាំងនោះ បានត្រូវអង្គការលីកាដូដឹកនាំយកទៅព្យាបាល ។ តាមរូបភាពរបស់លីកាដូ ដែលគេបញ្ជូនមកតាមគេហទំព័រ ឃើញប៉ូលិសលើកដំបងឆក់ដេញវាយព្រះសង្ឃ ។



*រូបថតប៉ូលិសកំពុងលើកជើងធាក់ព្រះសង្ឃ*

នេះពុំមែនជាល្ខោន គឺជាឆាកពិតរបស់អាជ្ញាធរខ្មែរបច្ចុប្បន្ន ដែលប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃមកលើព្រះសង្ឃព្រះពុទ្ធសាសនា ដែលជាស្ថាប័នជាទីសក្ការៈរបស់ជាតិខ្មែរ ហើយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ដោយអំពើគ្រាន់តែនិមន្តយកញត្តិទៅប្រគល់ឲ្យទូតយួន ដោយសន្តិវិធី ស្របតាមច្បាប់ជាតិនិងច្បាប់អន្តរជាតិប៉ុណ្ណោះ ។ ព្រះសង្ឃទាំងនោះគ្មានអាវុធក្នុងដៃ សូត្រធម៌ធ្វើសមាធិ ទើបនិមន្តចូលទៅ បំណងតែម្យ៉ាងគត់គឺប្រគល់ញត្តិ គ្មានទៅធ្វើចំបាំងទេ ហេតុអ្វីបានជាគេរៀបចំប៉ូលិសរាប់រយនាក់ដែលមានអាវុធគ្រប់ដៃ ទៅច្បាំងនឹងព្រះសង្ឃទៅវិញ ?

នេះពុំមែនជាលើកទីមួយទេ ដែលអាជ្ញាធរខ្មែរប្រព្រឹត្តដូច្នេះ សូមអាជ្ញាធរខ្មែរពិចារណាមើលខ្លួនឯង តើអំពើរបស់ខ្លួនបែបនេះចំណេញឬខាត ? មធ្យោបាយដែលល្អបំផុតគឺបើមិនចង់ឲ្យតំណាងព្រះសង្ឃ៥អង្គចូលទៅក្នុងទូតយួនទេ ប៉ូលិសទទួលយកលិខិត

របស់ព្រះសង្ឃទៅប្រគល់ឲ្យទូតយួនទៅជាការស្រេច គ្មានបញ្ហាកើតឡើងដូច្នេះឡើយ ហើយព្រះសង្ឃក៏ស្ងប់ព្រះទ័យនិមន្តទៅកុដិវិញហោង ។ សូមអាជ្ញាធរខ្មែរពិចារណាមើល បើមានបងប្អូនរបស់អាជ្ញាធរខ្លួនឯង មានទុក្ខត្រូវគេធ្វើបាបចាប់ដាក់គុកដោយអយុត្តិធម៌ តើអាជ្ញាធរខ្លួនឯងគិតយ៉ាងណាដែរ ? ដូចគ្នានេះដែរ ព្រះសង្ឃទាំងនេះមានក្តីរន្ធត់ដោយសារព្រះសង្ឃគ្នាលោក ត្រូវគេធ្វើទោសដោយអយុត្តិធម៌ ទើបចេញជាលិខិតទាមទារកុំឲ្យគេប្រព្រឹត្តដូច្នេះ នេះជាសិទ្ធិរបស់លោកក្នុងឋានៈជាព្រះសង្ឃខ្មែរ ម៉េចក៏ធ្វើមិនបាន បែរជាប្រព្រឹត្តអំពើហឹង្សា ដោយដេញវាយព្រះសង្ឃដូចជាវាយសត្វតិរច្ឆាន ។ អាជ្ញាធរខ្មែរល្មមភ្ញាក់ខ្លួន ស្គាល់អំពើល្អអំពើអាក្រក់ គួរធ្វើមិនគួរធ្វើហើយ ។ ប៉ុន្តែយើងយល់ថា អាជ្ញាធរខ្មែរពិតជាពុំធ្វើតាមការណែនាំរបស់ធម៌ព្រះពុទ្ធឡើយ គឺត្រូវតែស្តាប់បង្គាប់និងធ្វើតាមវៀតណាមវិញល្អជាង ។ មានទស្សនៈគេប្រាប់យើងថា ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម វាបានកន្លងផុតទៅហើយ មិនមានគ្រោះថ្នាក់ទៀតទេ ប៉ុន្តែបច្ចុប្បន្ននេះមានគ្រោះថ្នាក់ធ្ងន់បំផុត គឺវៀតណាមនៅតែមានអំណាចទៅលើអ្នកដឹកនាំខ្មែរ ។ គេឲ្យឧទាហរណ៍ថា ដូចជាសន្ធិសញ្ញាខុសច្បាប់ ធ្វើឲ្យត្រូវច្បាប់អំពីបញ្ហាទឹកដី ។ អន្តោប្រវេសន៍ចូលមកខុសច្បាប់ គ្មានការត្រួតពិនិត្យ, អភិវឌ្ឍន៍ត្រីកោណ, ប្រគល់ដីសម្បទានរាប់សែនហិកតាឲ្យវៀតណាមជាដើម ។ គេបន្ថែមថា បើកាត់ទោសខ្មែរក្រហមឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ត្រូវតែកាត់ទោសវៀតណាម ដែលចូលមកឈ្លានពានប្រទេសកម្ពុជាពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ផង ។ ព្រោះគោកទ្រព្យជាច្រើន ត្រូវវៀតណាមប្លន់យកទៅប្រទេសគេ ។ ចាប់ខ្មែរអ្នកស្នេហាជាតិដាក់គុកនិងសម្លាប់ ហើយពលរដ្ឋខ្មែរត្រូវស្លាប់ជាច្រើនក្នុងផែនការក-៥ ។

បញ្ហាមួយទៀត តាមធម្មតាប្រទេសដែលនៅក្រោមអាណានិគមនិយមបរទេស នៅពេលដែលបរទេសចាកចេញទៅ គេតែងតែប្តូរអ្នកដឹកនាំ ដើម្បីកុំឲ្យទាក់ទិនជាមួយបរទេស មានជាប់ដោយសន្ធិសញ្ញាជាដើម ប៉ុន្តែបក្សប្រជាជននៅតែបក្សប្រជាជនដដែល អ្នកដឹកនាំនៅតែដដែល គ្មានមានការដូរផ្លាស់ ។ ម្ល៉ោះហើយវៀតណាមនៅតែមានអំណាចលើបក្សប្រជាជន និងអ្នកដឹកនាំនេះដដែល ។ នេះជាទស្សនៈរបស់ខ្មែរខ្លះ សូមជនរួមជាតិពិចារណាមើល តើជាការត្រឹមត្រូវតាមទស្សនៈនេះឬទេ ? មានខ្មែរអ្នកយកចិត្តទុកដាក់អំពីបញ្ហាខ្មែរ បានខំប្រឹងប្រែងឲ្យគេយកសន្ធិសញ្ញាឆ្នាំ១៩៩១នៅទីក្រុងប៉ារីសស្តីអំពីកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជាមកពិនិត្យមើលឡើងវិញ តើអនុវត្តបានត្រឹមត្រូវឬទេរហូតមកទល់ពេលនេះ ព្រោះកិច្ចព្រមព្រៀងនេះជាដំណោះស្រាយទូទៅ មានការរក្សាបូរណភាពទឹកដីខ្មែរជាដើម ហើយបើគោរពសន្ធិសញ្ញានេះ ការដេញវាយព្រះសង្ឃរបស់អាជ្ញាធរខ្មែរនៅពេលនេះ ក៏ពុំកើតមានដែរ ។ យើងយល់ថា បើអ្នកដឹកនាំខ្មែរបច្ចុប្បន្ននេះរហូតព្រះមហាក្សត្រខ្មែរ គ្មានឆន្ទៈស្នើឲ្យសមាជិកទាំង១៨ប្រទេសប្រជុំគ្នា

ពិនិត្យឡើងវិញនូវភាពពេញលេញនៃការអនុវត្តនូវកិច្ចព្រមព្រៀងនោះទេ ពុំមានសង្ឃឹមថាបរទេសគេយកចិត្តទុកដាក់អំពីបញ្ហានេះឡើយ ព្រោះខ្មែរអ្នកមានអំណាចជាម្ចាស់ផ្ទះពុំរវីរវល់រឿងនេះ បរទេសគេយល់ថា ខ្មែរគ្មានបញ្ហាអ្វីទេ ។ ចំណែកសំណើរបស់ខ្មែរអ្នកមិនកាន់អំណាច អ្នកមិនទទួលខុសត្រូវ បរទេសមិនចាប់អារម្មណ៍ឡើយ ព្រោះបរទេសគេខ្លាចចោទគេថា ចូលជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ទោះគេដឹងថាការអនុវត្តន៍នូវសន្ធិសញ្ញានោះ ពុំបានត្រឹមត្រូវក៏ដោយ ក៏គេមិនអាចធ្វើអ្វីកើត ព្រោះម្ចាស់ផ្ទះដែលកាន់អំណាចពុំបានស្នើទៅគេ ។ វៀរលែងតែថៃឯនៃ្យបរទេសទាំងនោះ មានសហប្រធានទាំងពីរគឺបារាំងនិងឥណ្ឌូណេស៊ីស្នើរឿងនេះឡើង នោះជាសំណាងរបស់ខ្មែរ ប៉ុន្តែមិនសង្ឃឹមថា រឿងនេះអាចកើតឡើងដូច្នេះឡើយ ។ មិនត្រឹមតែពុំបានធ្វើសំណើទេ រាជរដ្ឋាភិបាល សភាទាំងពីរ និងព្រះមហាក្សត្រខ្មែរបានធ្វើសច្ចានុម័ត នូវសន្ធិសញ្ញាមិនស្របច្បាប់ឆ្នាំ១៩៨៥ ឲ្យស្របច្បាប់ទៅវិញ ។ ដូច្នេះអ្នកទទួលខុសត្រូវក្នុងការបាត់បង់ទឹកដីគឺស្ថាប័នទាំងបីរួមទាំងព្រះមហាក្សត្រផង ។ ច្បាប់នេះ គេអាចសើរើឡើងវិញ លុះត្រាតែមានរដ្ឋាភិបាលមួយថ្មី ដែលមានបំណងសើរើ ។

បែរមករៀបរាប់អំពីប៉ូលិសខ្មែរវាយបំបែកព្រះសង្ឃខ្មែរកម្ពុជាក្រោមបន្តទៅទៀតតាមសំដីមេប៉ូលិសថា ព្រះសង្ឃដែលនាំគ្នាយកញត្តិទៅឲ្យទូតយួននោះជាយុវជនស្មាវហើយគេនឹងតាមពិនិត្យក្រែងបួសក្លែងក្លាយ ។ នេះជាសំដីទំលច្រកដើម្បីសំឡុតស្មារតីព្រះសង្ឃ កុំឲ្យគេចាប់អារម្មណ៍អំពីអំពើឃោរឃៅ ដែលបញ្ជាឲ្យប៉ូលិសដេញវាយព្រះសង្ឃ ។ ព្រោះអ្នកណាក៏ដឹងថា ព្រះសង្ឃទាំងនោះជាអ្នកបួសត្រឹមត្រូវតាមធម៌វិន័យព្រោះមុននឹងឲ្យលោកស្នាក់នៅក្នុងវត្ត ចៅអធិការតែងតែពិនិត្យមើលឆាយា គឺឆាយានេះហើយដែលបញ្ជាក់ថាបួសត្រឹមត្រូវ ។ តាមពិត អ្នកដែលត្រូវត្រួតអង្កេត គឺក្រុមប៉ូលិសទាំងនោះវិញទេ តើមានយួនក្លែងក្លាយមកបន្លំធ្វើជាប៉ូលិស ដើម្បីវាយព្រះសង្ឃឬទេហើយប៉ូលិសណាខ្លះតាមវាយព្រះសង្ឃ និងជនណាដែលបញ្ជាឲ្យវាយព្រះសង្ឃ ។ ត្រូវតែយកជនដែលរំលោភសិទ្ធិមនុស្សវាយព្រះសង្ឃនោះ យកទៅកាត់ទោស ។ ត្រង់ពាក្យព្រះសង្ឃបានយកដបទឹកទៅវាយតបប៉ូលិសវិញ យើងយល់ថាដបទឹកនោះ ព្រះសង្ឃយកទៅឆាន់ ព្រោះប្រទេសខ្មែរក្តៅ គ្មានបំណងយកទៅវាយប៉ូលិសទេ ចុះប៉ូលិសស្ពាយកាំភ្លើងគ្រប់គ្នានោះ តើទៅវាយខ្លាំងណា ឬទុកព្រះសង្ឃជាខ្មាំង ។ ការតបតទៅវិញនោះទំនងជាព្រះសង្ឃទាំងនោះអត់ទ្រាំលែងបានដោយអំពើព្រៃផ្សៃរបស់ប៉ូលិសទាំងនោះ ។ តំណាងទូតយួនលួចមើលតាមបង្អួចដោយញញឹម ទំនងជានឹកក្នុងចិត្តថា កូនចៅអញធ្វើតាមបញ្ជាអញហើយ អញមិនបាច់និយាយឆ្លើយឆ្លងអ្វីទេ អាខ្មែរអស់នេះល្ងង់ណាស់ អញគ្រាន់តែញុះបន្តិច វាវាយប្រហារគ្នាវា សូម្បីតែព្រះសង្ឃជាអ្នកស្លូតត្រង់ ក៏តាមវាយប្រហារដែរ ។៚